ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ៧ លេខ ៩០ សប្តាហ៍ទី ១ ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

កម្ពុជា

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាមុន)

348.033
CAM

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

ក

មាតិកា

I_រាជរដ្ឋាភិបាល

១_អនុក្រឹត្យ

០៥-១២-២០០៧ -អនុក្រឹត្យ លេខ ១៨៥ អនក្រ.បក ស្ដីពីការកែសម្រួលប្រាក់បៀវត្សមូលដ្ឋាន របស់កងយោធពលខេមរភូមិន្ទ ៥៥២៣

០៥-១២-២០០៧ -អនុក្រឹត្យ លេខ ១៨៦ អនក្រ.បក ស្ដីពីការផ្ទេរឥណទានថវិកា ៥៥២៦

០៥-១២-២០០៧ -អនុក្រឹត្យ លេខ ១៨៧ អនក្រ.បក ស្ដីពីការផ្ដល់ឥណទានថវិកាបន្ថែមជូនរដ្ឋសភាសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ៥៥២៨

០៥-១២-២០០៧ -អនុក្រឹត្យ លេខ ១៨៨ អនក្រ.បក ស្ដីពីការផ្ទេរឥណទានថវិកា ៥៥៣០

០៥-១២-២០០៧ -អនុក្រឹត្យ លេខ ១៨៩.អនក្រ.បក ស្ដីពីការផ្ទេរឥណទានថវិកា ៥៥៣២

០៦-១២-២០០៧ -អនុក្រឹត្យ លេខ ១៩០ អនក្រ.បក ស្ដីពីការផ្ទេរឥណទានថវិកា ៥៥៣៤

០៦-១២-២០០៧ -អនុក្រឹត្យ លេខ ១៩១ អនក្រ.បក ស្ដីពីការផ្ទេរឥណទានថវិកា ៥៥៣៦

០៤-១២-២០០៧ -អនុក្រឹត្យ លេខ ៥៤៩ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ៥៥៣៨

០៤-១២-២០០៧ -អនុក្រឹត្យ លេខ ៥៥០ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៥៥៣៩

០៤-១២-២០០៧ -អនុក្រឹត្យ លេខ ៥៥១ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៥៥៤០

០៤-១២-២០០៧ -អនុក្រឹត្យ លេខ ៥៥២ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៥៥៤១

២_សេចក្ដីសំរេច

០៧-១២-២០០៧ -សេចក្ដីសំរេចលេខ ៦៥ សសរ ស្ដីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៥៥៤២

II_ការងារបណ្ដាក្រសួង

១_ទីស្ដីការក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

២៨-១១-២០០៧ -ប្រកាសលេខ ១២១៩ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន អេស៊ា កែក (ខេមបូឌា) បង្កើតរោងចក្រ " ផលិតកញ្ចប់សំរាប់វេចខ្ចប់ផលិតផល " ដែលមានឈ្មោះថា " អេស៊ា កែក (ខេមបូឌា)" ៥៥៤៣

២-នីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ក្រសួងយុត្តិធម៌

សេចក្តីណែនាំ

២៧-៧-២០០៧ -សេចក្តីណែនាំអន្តរក្រសួងលេខ ០១០ សណន.មផ.កយ/០៧ ស្តីពីការកែតម្រូវ និង បំពេញចំណុចខ្វះខាតនៅក្នុងសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ ៥៥៤៥

៣-នីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៣-៣-២០០៧ -លិខិតបញ្ជាក់លេខ ១២២០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វ្រាយអិន ស៊ុង** ៥៥៦០

២៦-៣-២០០៧ -លិខិតបញ្ជាក់លេខ ១២២២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធី.ធី.យូ.អ៊ិមផត អិចផត** ៥៥៦២

២៦-៣-២០០៧ -លិខិតបញ្ជាក់លេខ ១២២៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឃុយ គាត ឃ្លាំមេង** ៥៥៦៤

២៦-៣-២០០៧ -លិខិតបញ្ជាក់លេខ ១២២៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ុនលី អ៊ីមផត អិចផត អេន ត្រេនស្ព័ត គីធីអ៊ី អិលធីឌី** ៥៥៦៦

២៦-៣-២០០៧ -លិខិតបញ្ជាក់លេខ ១២២៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ពិសិដ្ឋ ខនស្ត្រាក់សិន & ឌីវេឡុបមេន** ៥៥៦៨

២៦-៣-២០០៧ -លិខិតបញ្ជាក់លេខ ១២៣០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិន ធី អេស អេ** ៥៥៧០

២៦-៣-២០០៧ -លិខិតបញ្ជាក់លេខ ១២៣២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធី ទី ខេ ស៊ី ខបភើរេសិន** ៥៥៧២

២៧-៣-២០០៧ -លិខិតបញ្ជាក់លេខ ១២៣៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ចិន អន ហេង សំណង់ ខនស្ត្រាក់សិន** ៥៥៧៤

២៧-៣-២០០៧ -លិខិតបញ្ជាក់លេខ ១២៣៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេ ឌី អេ អេនជីនារីង** ៥៥៧៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៨៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកែសម្រួលប្រាក់បៀវត្សមូលដ្ឋាន របស់កងយោធពលខេមរភូមិន្ទ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្ស របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការកែសម្រួលប្រព័ន្ធបៀវត្ស របស់កងយោធពលខេមរភូមិន្ទ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១ : អនុក្រឹត្យនេះមានគោលដៅកែសម្រួលប្រាក់បៀវត្សមូលដ្ឋាន របស់កងយោធពលខេមរភូមិន្ទ ។

មាត្រា២ : ប្រាក់បៀវត្សមូលដ្ឋាន របស់កងយោធពលខេមរភូមិន្ទគឺត្រូវបានបែងចែកតាមលំដាប់ថ្នាក់នៃឋានន្តរស័ក្តិ និងត្រូវផ្តល់ទៅតាមសន្ទស្សន៍ ដូចមានកំណត់ក្នុងតារាងខាងក្រោម ÷

ល.រ	ឋានន្តរស័ក្តិ	កំរិតសន្ទស្សន៍ប្រាក់បៀវត្ស	សេចក្តីផ្សេងៗ
១	នាយឧត្តមសេនីយ៍ - នាយឧត្តមនាវី	៥៥០	
២	ឧត្តមសេនីយ៍ឯក - ឧត្តមនាវីឯក	៥៣០	
៣	ឧត្តមសេនីយ៍ទោ - ឧត្តមនាវីទោ	៥១០	
៤	ឧត្តមសេនីយ៍ត្រី - ឧត្តមនាវីត្រី	៤៥០	
៥	វរសេនីយ៍ឯក - វរនាវីឯក	៤៤២	
៦	វរសេនីយ៍ទោ - វរនាវីទោ	៤១០	
៧	វរសេនីយ៍ត្រី - វរនាវីត្រី	៣៧០	
៨	អនុសេនីយ៍ឯក - អនុនាវីឯក	៣៣៦	
៩	អនុសេនីយ៍ទោ - អនុនាវីទោ	៣០៨	
១០	អនុសេនីយ៍ត្រី - អនុនាវីត្រី	២៨០	
១១	នាយចំណង់ - នាយនាវីចំណង់	២៤៥	
១២	ព្រឹន្ទបាលឯក - នាយចក្របាលឯក	២៣៣	
១៣	ព្រឹន្ទបាលទោ - នាយចក្របាលទោ	១៩៣	
១៤	ពលបាលឯក - ចក្របាលឯក	១៧១	
១៥	ពលបាលទោ - ចក្របាលទោ	១៦៣	
១៦	ពលបាលត្រី - ចក្របាលត្រី	១៥៥	
១៧	នាយឯក - ចក្របាលរងឯក	១៣៤	
១៨	នាយទោ - ចក្របាលរងទោ	១២៥	
១៩	ពលឯក - នាវិកឯក	១១៩	
២០	ពលទោ - នាវិកទោ	១១៣	

មាត្រា៣ :តម្លៃឯកតាសន្ទស្សន៍សម្រាប់អនុវត្ត និងការកែប្រែត្រូវអនុវត្តតាមអនុក្រឹត្យ ស្តីពីតម្លៃឯកតានៃសន្ទស្សន៍ របស់មន្ត្រីរាជការស៊ីវិល ។

មាត្រា៤ : យោធិនដែលមានសិទ្ធិទទួលប្រាក់បៀវត្សក្នុងកងយោធពលខេមរភូមិន្ទ ត្រូវស្ថិតក្នុងលក្ខខ័ណ្ឌដូចខាងក្រោម ÷

១- កំពុងបំពេញការងារក្នុងកងយោធពលខេមរភូមិន្ទ ។

២- កំពុងផ្លាស់ប្តូរកន្លែងធ្វើការ និងកំពុងធ្វើដំណើរទៅកាន់មុខតំណែង នៅក្នុង ឬក្រៅប្រទេស ។

៣- កំពុងបំពេញការសិក្សានៅក្នុង និងក្រៅប្រទេសតាមតម្រូវការរបស់កងទ័ព ។

៤- យោធិនពលី ពិការ និវត្តន៍ជន ដែលមិនទាន់ផ្ទេរទៅឱ្យក្រសួងទទួលបន្ទុកអតីតយុទ្ធជន គ្រប់គ្រងបន្ត ។

៥- យោធិនដែលអនុញ្ញាតច្បាប់ក្នុងចុះផ្ទាល់ រយៈពេលសំរាកព្យាបាលជម្ងឺ និងបាត់ខ្លួនក្នុងបេសកកម្ម ។

មាត្រា៥ : ការបញ្ឈប់ផ្តល់ប្រាក់បៀវត្ស ត្រូវធ្វើទៅតាម ថ្ងៃ ខែ ដែលបានកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ក្នុងករណីដូចខាងក្រោម ៖

១- យោធិនដែលសុំលាឈប់ពីការងារ ដោយមានការអនុញ្ញាត ។

២- យោធិនដែលមានប្រកាសបណ្តេញចេញពីកងយោធពលខេមរភូមិន្ទ ។

៣- យោធិនដែលអវត្តមានគ្មានការអនុញ្ញាត ឬហួសកំណត់ដោយសំអាងលើប្រធានស័ក្តិដែលមិនសមស្រប ។

៤- យោធិនពលី ពិការ និវត្តន៍ជន ដែលបានផ្ទេរទៅឱ្យក្រសួងទទួលបន្ទុកអតីតយុទ្ធជន គ្រប់គ្រងបន្តរួចហើយ ។

៥- យោធិនដែលមានសាលក្រមរបស់តុលាការបញ្ជាក់ថាជាទណ្ឌិត ។

មាត្រា៦ : ប្រាក់របបផ្សេងៗទៀត ក្រៅពីប្រាក់បៀវត្សមូលដ្ឋាន ត្រូវបន្តអនុវត្តជាធរមាន ។

មាត្រា៧ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

សូមចុះហត្ថលេខា

រដ្ឋមន្ត្រី ក្រសួងការពារជាតិ

ទៀ បាញ់

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៥៧៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧. ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤. ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ១០/នស/៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែល ប្រកាសអោយប្រើដោយ ព្រះរាជ ក្រមលេខ នស/រកម/១២០២/០២០.ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និង ប្រកាសលេខ ១៤០១ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃ មាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក.ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសំរួលដោយនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៤០១ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- យោងលិខិត ១៥០០ កប ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៧ របស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា ១ : ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ១.៥០៩.១១០.០០០ រៀល (មួយពាន់ប្រាំរយប្រាំបួនលាន មួយរយដប់ពាន់រៀលគត់) ក្នុងនោះផ្ទេរចេញពីជំពូក ៦១ (សេវាខាងក្រៅ) ចំនួន ៤៧៤.០១០.០០០ រៀល, ជំពូក ៦២ (សេវាខាងក្រៅផ្សេងៗ) ចំនួន ៧៧១.១០០.០០០ រៀល, ជំពូក ៦៥ (ឧបត្ថម្ភកធន និងជំនួយសង្គម) ចំនួន ២៥៨.៤០០.០០០ រៀល និងជំពូក ៦៣ (ពន្ធ និងអាករ) ចំនួន ៥.៦០០.០០០ រៀល មកជំពូក ៦០ (ការទិញ) ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា ២ : ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះទៅ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់ចំណាយទិញសំភារៈការិយាល័យ និងការបោះពុម្ព ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាល វិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ ✓

បានយកសេចក្តីជំរាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៨៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់ឥណទានថវិកាបន្ថែម

ជូនរដ្ឋសភា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ,ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១: ដោយអនុលោមទៅតាមមាត្រា ៤៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១/នស/៩៣ . ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ត្រូវបានអនុញ្ញាតផ្តល់បន្ថែមឥណទានថវិកា ចំនួន ១.១៥០ លានរៀល (មួយពាន់មួយរយហាសិបលានរៀលគត់) ទៅលើសៀវភៅថវិការបស់រដ្ឋសភា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា២: ឥណទានថវិកាបន្ថែមដូចក្នុងមាត្រា ១ ខាងលើ ត្រូវបានបន្ថែមនៅជំពូក ៦២ (សេវាខាងក្រៅផ្សេង១) របស់រដ្ឋសភា សំរាប់ទូទាត់បុរេប្រទានក្នុងពិធីរៀបចំសម្ពោធវិមានរដ្ឋសភាថ្មី ។

មាត្រា៣: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា៤: ឥណទានថវិកាបន្ថែមនេះ ត្រូវបានរដ្ឋសភាពិនិត្យអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុ នាពេលខាងមុខ កាលបើការបោះអាណត្តិទូទាត់ចំណាយរៀបចំសម្ពោធវិមានរដ្ឋសភាថ្មីត្រូវបានចប់សព្វគ្រប់ ។

មាត្រា៥: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្តេចប្រធានរដ្ឋសភា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៨៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧, ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤, ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ រៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ១០/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែល ប្រកាសអោយប្រើដោយ ព្រះរាជ ក្រមលេខ នស/រកម/១២០២/០២០,ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និង ប្រកាសលេខ ១៤០១ សហវ.ប្រកចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃ មាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក.ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសំរួលដោយនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅ របស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

ប្រការ ១ : ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាសរុបចំនួន ៣១៤.៦០០.០០០ រៀល (បីរយដប់បួនលានប្រាំមួយរយពាន់រៀលគត់) ក្នុងនោះផ្ទេរចេញពីជំពូក ៦០ (ការទិញ)ចំនួន ១៣៦.៦០០.០០០ រៀល (មួយរយសាមសិបប្រាំមួយលាន ប្រាំមួយរយពាន់រៀលគត់),ជំពូក ៦១ (សេវាខាងក្រៅ) ចំនួន ១៧៨.០០០.០០០ រៀល (មួយរយចិតសិបប្រាំបីលានរៀលគត់) មក ជំពូក ៦២ (សេវាកម្មខាងក្រៅផ្សេងៗ)ចំនួន ២៨៤.២០០.០០០ រៀល(ពីររយប៉ែតសិបបួនលាន ពីររយពាន់រៀលគត់) ជំពូក ៦៤(បន្ទុកបុគ្គលិក)ចំនួន ៣០.៤០០.០០០ រៀល (សាមសិបលាន បួនរយពាន់រៀលគត់) ជូនក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

ប្រការ ២ : ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះទៅ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់កែសំរួលដល់តំរូវការចំណាយជាក់ស្តែងអោយសមស្របតាម ជំពូក គណនី អនុគណនី ។

ប្រការ ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៧

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

ក្រសួងព្រះបរមរាជវាំង

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋានរដ្ឋសភា

ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ

ហ៊ុន សែន នាយករដ្ឋមន្ត្រី

ដូចមាត្រា ៣

កាលប្បវត្តិ — ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៧៩៩ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ,ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ២.៩៦០ លានរៀល (ពីរពាន់ប្រាំរយហុកសិបលានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦០ (ការទិញ) ជូនក្រសួងមហាផ្ទៃ-ផ្នែកសន្តិសុខសាធារណៈ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់បំពេញបន្ថែមទូទាត់ថ្លៃផ្គត់ផ្គង់អង្ករឆមាសទី ២ ឆ្នាំ ២០០៧ ជូនក្រុមហ៊ុន ខូន ឌុន្នី គ្រេឌីន ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៩០ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧, ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤, ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ រៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ១០/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែល ប្រកាសអោយប្រើដោយ ព្រះរាជ ក្រមលេខ នស/រកម/១២០២/០២០.ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និង ប្រកាសលេខ ១៤០១ សហវ.ប្រក្សចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃ មាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក.ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសំរួលដោយនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅ របស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

ប្រការ ១ : ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ៣២៨.៩០០.០០០រៀល (បីរយម្ភៃប្រាំបីលានប្រាំបួនរយពាន់រៀលគត់) ក្នុងនោះផ្ទេរចេញពីជំពូក ៦១ (សេវាខាងក្រៅ) ចំនួន ១៩.៦៧០.០០០ រៀល.ជំពូក ៦២ (សេវាខាង ក្រៅផ្សេងៗ) ចំនួន ២៩៧,០៣០.០០០រៀល. និងជំពូក ៦៥ (ឧបត្ថម្ភកធន និងជំនួយសង្គម) ចំនួន ១២.២០០.០០០រៀល មកជំពូក ៦០ (ការទិញ) ជូនក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

ប្រការ ២ : ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះទៅ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាស របស់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់ចំណាយទិញសំភារៈការិយាល័យ និងបោះពុម្ព ។

ប្រការ ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះ បណ្តាល វិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ៦ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u>

- ឋបងព្រះបរមរាជវាំង
- លេខាធិការដ្ឋានព្រឹទ្ធសភា
- លេខាធិការដ្ឋានរដ្ឋសភា
- កាលិយសម្តេចអគ្គមហាសេនាបតីតេជោ
- រ សែន នាយករដ្ឋមន្ត្រី
- មាត្រា ៣
- បប្បវត្តិ – ឯកសារ ✓

បានយកសេចក្តីជំរាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៩១ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ . ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ .ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ . ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក .ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ១០១.០០០.០០០ រៀល (មួយរយមួយលានរៀលគត់) ពីជំពូក ៦០ (ការទិញ) មកជំពូក៦៥ (ឧបត្ថម្ភកធន និង ជំនួយសង្គម) ជូនក្រសួងមហាផ្ទៃ-ផ្នែកសន្តិសុខសាធារណៈ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីផ្តល់ជូនក្រសួងមហាផ្ទៃ-ផ្នែកសន្តិសុខសាធារណៈ សំរាប់បន្ថែមអាហារូបករណ៍សំរាប់ការសិក្សា និង ស្រាវជ្រាវក្នុងប្រទេសឆ្នាំ ២០០៧ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៧

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...១៥៤១.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយសហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១ ៖ ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនលោក **ONO Tomohiro** ជំនួយការឯកឧត្តម ប្រធានអង្គការ **JICA** ប្រចាំនៅកម្ពុជា ដែលមានស្នាដៃល្អក្នុងការធ្វើសហប្រតិបត្តិការ ជួយស្តារនិងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ វិស័យគមនាគមន៍ និងដឹកជញ្ជូន នៅព្រះរាជាណាចក្រកម្ពុជា ។

មាត្រា២ៈ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១៥៤០...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពត៌មាន

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ ជូនឯកឧត្តម អស់លោកជាមន្ត្រីរាជការក្រសួងពត៌មាន ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចជូនជាតិ បានល្អប្រសើរ ដូចមានរាយនាមខាងក្រោម

១-ឯកឧត្តម	ស៊ុខ ចំរើន	ទីប្រឹក្សាក្រសួងពត៌មាន
២-ឯកឧត្តម	អ៊ុក គីមសេង	ទីប្រឹក្សាក្រសួងពត៌មាន
៣-ឯកឧត្តម	ឡុង សេង	ទីប្រឹក្សាក្រសួងពត៌មាន
៤-លោក	លី ចាន់ហុង	អគ្គនាយករង AKP
៥-លោក	គួច សារ៉ើត	អគ្គនាយករងវិទ្យុជាតិ

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងពត៌មាន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និងមាត្រា ២
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...៩៦...អនក្រ.បក

អនុក្រឹត្យ

ស្ដីពីការជូនមេដាយស្ថាបនាជាតិ

៙៙៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៨ រូប ដែលបានបរិច្ចាគធនធាន ជួយកសាងអគារមន្ទីរពេទ្យ ០១ខ្នង ផ្លូវមួយខ្សែ ចម្ងាយ១៥ គីឡូម៉ែត្រ និងដាក់លូ ចំនួន ០៧កន្លែង នៅក្នុងតំបន់អភិវឌ្ឍន៍កងទ័ពជើងគោក ភូមិអន្លង់ក្រពើ ឃុំជើងគោ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ចំណាយអស់ថវិកាសរុប ចំនួន ៩៧.៤៥០ ដុល្លារ ដូចមានរាយនាមខាងក្រោម :-

១-លោក គង់ សារ៉ាន់

២-លោក ឡុង ទ៉ាន់

៣-លោក ទោវ ស៊ីវឿន

៤-MR. HONG SIHWAN

៥-MRS. CHO HAE OK

៦-MR., PRICHA SAEKANG

៧-MR . SUVINAI RANDAVAY

៨-MR. BANPOT DUANG CHANA

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ៦ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា ១ និង មាត្រា ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ...[illegible] អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ចំនួន ០៨រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលនានា ក្នុងទីអារាមវត្តវៀរវិន្តស្វាយមានលក្ខណ៍ ស្ថិតក្នុងឃុំស្វូទិប ស្រុកជើងព្រៃ ខេត្តកំពង់ចាម ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-ព្រះភិក្ខុ	ហង្ស ហោត	បច្ច័យ ចំនួន ១០.៥០០ ដុល្លារអាមេរិក
២-លោក	ជា លីម៉េង	ថវិកា ចំនួន ២១.៨០៥ ដុល្លារអាមេរិក
៣-លោកស្រី	ឈូ លីយី	ថវិកា ចំនួន ២០.០៧០ ដុល្លារអាមេរិក
៤-លោក	ស៊ូ ឡុង	ថវិកា ចំនួន ១០.០០០ ដុល្លារអាមេរិក

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

១-លោក	ឌិច ទីត្រី	ថវិកា ចំនួន ៥.៥០០ ដុល្លារអាមេរិក
២-លោកស្រី	ស៊ីសុវត្ថ នារីផល	ថវិកា ចំនួន ៥.២០០ ដុល្លារអាមេរិក
៣-លោក	សំ មើន	ថវិកា ចំនួន ៥.១៤០ ដុល្លារអាមេរិក

គ-មេដាយសំរិទ្ធស្ថាបនាជាតិ :

-លោក	សាយ អេចឈៀង	ថវិកា ចំនួន ៣.០០០ ដុល្លារអាមេរិក

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៧
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៦៥...សសរ

សេចក្ដីសំរេច

ស្ដីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្ដីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្ដេចនាយករដ្ឋមន្ត្រីដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋឥណ្ឌា ចាប់ពីថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០០៧ រហូតដល់សម្ដេចនាយករដ្ឋមន្ត្រីអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្ដីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែៈ

<u>កន្លែងទទួល :</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ ២

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៨៤៦.១៩ ឧ.រ.ថ.ករ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៧

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៤១២១/០៧ គ.វ.ក ចុះថ្ងៃទី៣០.១០.២០០៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើ របស់ក្រុមហ៊ុន អេស៊ា ភែក (ខេមបូឌា) ចុះថ្ងៃទី០៨.១០.២០០៧

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន អេស៊ា ភែក (ខេមបូឌា) (ASIA PACK (CAMBODIA) CO., LTD. តំណាងដោយលោក SUZUKI EIJI សញ្ជាតិជប៉ុន អាយុ៥៩ឆ្នាំ កាន់លិខិតឆ្លងដែនលេខ TH3764722 ចុះថ្ងៃទី០៤.០៧.២០០៧ បង្កើតរោងចក្រ "ផលិតកញ្ចប់សំរាប់វេចខ្ចប់ផលិតផល" ដែលមានឈ្មោះថា "អេស៊ា ភែក (ខេមបូឌា) (ASIA PACK (CAMBODIA))" ដែលមានទីតាំងស្ថិតនៅ សួនឧស្សាហកម្មកាណាឌីយ៉ា អាគារលេខ៣៧ ផ្លូវវែងស្រេង ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ២: មុនចាប់ផ្តើមដំណើរការរោងចក្រ ក្រុមហ៊ុនត្រូវជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបានមុនរយៈពេល១៥ថ្ងៃ និងត្រូវរៀបចំរោងចក្រ ទៅតាមប្លង់ដែលបានតម្កល់ទុក នៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "ផលិតកញ្ចប់សំរាប់វេចខ្ចប់ផលិតផល" ហើយត្រូវផ្តល់ទិន្នន័យ និង របាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ តាមមាត្រា១៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្មជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់១ឆ្នាំក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន-អេស៊ា ភែក (ខេមបូឌា) ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ **ក្រសួងយុត្តិធម៌**

លេខ ០១០ សរ.សា.ស.ស.ន.កបប/០៧

លិខិតចូល
ថ្ងៃទី.........ខែ.........ឆ្នាំ២០០៧

សេចក្ដីណែនាំអន្តរក្រសួង
ស្ដីពី
ការកែតម្រូវ និង បំពេញចំណុចខ្វះខាត
នៅក្នុងសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ

អនុលោមតាមអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្ដីពីអត្រានុកូលដ្ឋាន ការចុះបញ្ជីអត្រានុកូលដ្ឋានតាមគំរូថ្មីឯកភាព ត្រូវបានដាក់ឱ្យដំណើរការក្នុងក្របខ័ណ្ឌជាតិទាំងមូល ចាប់តាំងពីថ្ងៃទី០១ ខែ សីហា ឆ្នាំ ២០០២ មក ។ ក្នុងរយៈពេលនេះ ដើម្បីលើកកម្ពស់ការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទជូនប្រជាពលរដ្ឋ រាជរដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតឱ្យបង្កើតនូវយុទ្ធនាការចុះបញ្ជីអត្រានុកូលដ្ឋានចល័តចំនួន ០៣ លើកជាប់ៗគ្នា ចាប់តាំងពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៤ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៦ ។

ផ្អែកតាមគោលនយោបាយ និង វិធានការទាំងនេះ រួមនឹងការខិតខំប្រឹងប្រែងដោយផ្ទាល់របស់អាជ្ញាធរឃុំ សង្កាត់ទូទាំងប្រទេស ដោយមានការគាំទ្រពីក្រសួង ស្ថាប័ននានានៅថ្នាក់ជាតិ អាជ្ញាធរខេត្ត ក្រុង ស្រុក ខណ្ឌ ព្រមទាំងអង្គការជាតិ និង អន្តរជាតិនានា បានធ្វើឱ្យការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទជូនប្រជាពលរដ្ឋសម្រេចបានលទ្ធផលគួរជាទីមោទនៈ ។

ប៉ុន្តែប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានតាមគំរូថ្មីឯកភាព ជាកិច្ចការថ្មីថ្មោង ការបណ្ដុះបណ្ដាល កសាងសមត្ថភាពធ្វើឡើងរយៈពេលខ្លី ចំពោះមន្ត្រីរាជការទទួលកិច្ចការនេះក៏មានចំនួនតិចតួចនៅឡើយ រីឯការអប់រំសាធារណជនក៏ធ្វើឡើងមិនទាន់បានទូលំទូលាយ ហើយការចុះបញ្ជីអត្រានុកូលដ្ឋាន បានធ្វើឡើងក្នុងលក្ខណៈប្រញាប់ប្រញាល់ នៅក្នុងដំណាក់កាលនៃការចុះបញ្ជីអត្រានុកូលដ្ឋានចល័ត ជាហេតុធ្វើឱ្យមានការខុសឆ្គង និង ការភ័ន្តច្រឡំមួយចំនួនក្នុងការស្រង់ព័ត៌មានរបស់ប្រជាពលរដ្ឋ បញ្ចូលទៅក្នុងបញ្ជីអត្រានុកូលដ្ឋាន ដូចជា : នាមត្រកូល នាមខ្លួន ថ្ងៃ ខែ ឆ្នាំកំណើត សាក្សី ឈ្មោះខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ ជាដើម ...។ល។

ការខុសឆ្គង និង ការភ័ន្តច្រឡំទាំងនេះ ចាំបាច់ត្រូវធ្វើការកែតម្រូវឱ្យបានត្រឹមត្រូវ និង ទាន់ពេលវេលាដើម្បីកត់ត្រាអោយបានពិតប្រាកដ នូវស្ថានភាពជាក់ស្ដែង និង ស្របច្បាប់របស់បុគ្គលម្នាក់ៗ ដែលចុះនៅក្នុងសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ ។ ទន្ទឹមនេះ ការផ្លាស់ប្ដូរណាមួយមកលើឋានៈ និង ស្ថានភាពរបស់បុគ្គលម្នាក់ៗតាមការសម្រេចរបស់តុលាការក៏ចាំបាច់ត្រូវធ្វើការកត់ត្រាចូលក្នុងបញ្ជីអត្រានុកូលដ្ឋានឱ្យបានត្រឹមត្រូវផងដែរ ។

អនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០០ ស្ដីពីអត្រានុកូលដ្ឋាន ជំពូកទី ៣ មាត្រា ១៣

បានចែងអំពីនីតិវិធីកែតម្រូវសៀវភៅអត្រានុកូលដ្ឋាន ។ ទន្ទឹមនេះ មាត្រា៩ នៃអនុក្រឹត្យខាងលើ ក៏បានកំណត់អំពីភារកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋាន ដែលក្នុងនោះមានទាំងការកែតម្រូវអក្ខរាវិរុទ្ធ និង ការកែតម្រូវ ឬ បដិសេធអត្រានុកូលដ្ឋាន តាមអំណាចសាលក្រមស្ថាពរ របស់តុលាការ ។ មាត្រា ២១ នៃអនុក្រឹត្យនេះក៏បានកំណត់អំពីភារកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋាន ក្នុងការចុះកិច្ចសន្យាសុំកូន នៅក្នុងសៀវភៅអត្រានុកូលដ្ឋានផងដែរ ។

ដើម្បីកែតម្រូវការខុសឆ្គង ការភ័ន្តច្រឡំនានានៅក្នុងសៀវភៅអត្រានុកូលដ្ឋាន ដែលបានប្រើប្រាស់កន្លងមក និង ការកែតម្រូវ និង បដិសេធអត្រានុកូលដ្ឋាន តាមអំណាចសាលក្រមស្ថាពររបស់តុលាការ និង ការចុះកិច្ចសន្យាសុំកូនយកទៅចិញ្ចឹម នៅក្នុងសៀវភៅអត្រានុកូលដ្ឋាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សូមធ្វើការណែនាំដូចខាងក្រោម ៖

១- លក្ខខណ្ឌនៃការកែតម្រូវ :

ការកែតម្រូវលើការខុសឆ្គង ការភ័ន្តច្រឡំ និង ការបំពេញបន្ថែមនៅក្នុងសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ ត្រូវធ្វើឡើងតាមលក្ខខណ្ឌដូចតទៅ ៖

ក- កែតម្រូវ ការសរសេរខុស ឬ ការភ័ន្តច្រឡំដោយអចេតនា ដោយមិនប៉ះពាល់មកលើ ឋានៈ ស្ថានភាព និង សាវតាររបស់សាមីជន និង អ្នកពាក់ព័ន្ធ ដែលបានកត់ត្រារួចហើយ ឬ កំពុងកត់ត្រានៅក្នុងសៀវភៅអត្រានុកូលដ្ឋាន

ខ- កែតម្រូវ ឬ បដិសេធអត្រានុកូលដ្ឋាន តាមសាលក្រមស្ថាពរ របស់តុលាការ

គ- ការព្យួរទុកជាបណ្តោះអាសន្ន នូវបញ្ជីនៅក្នុងសៀវភៅអត្រានុកូលដ្ឋានដោយមន្ត្រីអត្រានុកូលដ្ឋាន ឬ មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាននៅសាលាស្រុក ខណ្ឌ ឬ នៅតុលាការខេត្ត ក្រុង ដោយបញ្ជីអត្រានុកូលដ្ឋាននោះ សរសេរខុសច្រើនពេក ឬ លុបច្រើនពេក ហើយដែលមិនបានកែតម្រូវ ឱ្យស្របតាមការកំណត់ ត្រង់ជំពូកទី៣ មាត្រា១៣ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន ឬ នៅពេលពិនិត្យសៀវភៅអត្រានុកូលដ្ឋាន ហើយសាមីខ្លួន ឬ អាណាព្យាបាល ឬ សាក្សីមិនបានផ្តល់ព័ត៌មាន ឱ្យបាន ទាន់ពេលវេលា

ឃ- ដកហូតសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម និង សេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន រួចហើយត្រូវចុះបញ្ជីអត្រានុកូលដ្ឋានជូនជាថ្មី ក្នុងករណីមានការខុសឆ្គងដោយអចេតនា

ង- ក្នុងករណីមានការខុសឆ្គងដោយចេតនា អាស្រ័យដោយមានការឃុបឃិត ក្លែងបន្លំ ត្រូវដកហូតសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម និង សេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន រួចហើយត្រូវរាយការណ៍អោយភ្នាក់ងារមានសមត្ថកិច្ចរៀបចំសំណុំរឿង ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ ។

២- អំពីការកែតម្រូវ ការបំពេញបន្ថែម ការព្យួរទុកជាបណ្តោះអាសន្ន និង ការបដិសេធ :

ការកែតម្រូវ ការបំពេញបន្ថែម ការព្យួរទុកជាបណ្តោះអាសន្ន និង ការបដិសេធ នូវបញ្ជីនៅក្នុងសៀវភៅអត្រានុកូលដ្ឋាន ត្រូវយោងទៅ តាមករណីដូចខាងក្រោម ៖

ក- តាមការស្នើសុំរបស់មន្ត្រីអត្រានុកូលដ្ឋាន ចំពោះសៀវភៅអត្រានុកូលដ្ឋានដែលកំពុងប្រើប្រាស់

ខ-តាមការស្នើសុំរបស់មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាននៅសាលាស្រុក ខណ្ឌ ឬ នៅតុលាការខេត្ត ក្រុង ដែលបានចាត់តាំងឱ្យធ្វើការត្រួតពិនិត្យសៀវភៅអត្រានុកូលដ្ឋាន ហើយបានរកឃើញនូវការខុសឆ្គង ឬ ការភ័ន្តច្រឡំ នៅក្នុងបញ្ជីអត្រានុកូលដ្ឋាន ដែលបានកត់ត្រារួច ក្នុងឆ្នាំដែលកន្លងទៅ ។

គ- តាមការទាមទាររបស់សាមីខ្លួន ឬ អ្នកអាណាព្យាបាល (ក្នុងករណីអត្រានុកូលដ្ឋានរបស់អនីតិជន)

ឃ- តាមសាលក្រមស្ថាពររបស់តុលាការ

៣- អំពីទិន្នន័យ :

ក្នុងការកែតម្រូវ និង បំពេញបន្ថែមទិន្នន័យ ដែលជាព័ត៌មាននានា នៅក្នុងបញ្ជីអត្រានុកូលដ្ឋាន ត្រូវធ្វើការបែងចែកជា ទិន្នន័យសំខាន់ និង ទិន្នន័យបន្ទាប់បន្សំ ។

ក- ទិន្នន័យសំខាន់ រួមមាន ៖

- នាមត្រកូល នាមខ្លួន សញ្ជាតិ របស់សាមីខ្លួន ឪពុក ម្ដាយ និង សាក្សី

- ថ្ងៃ ខែ ឆ្នាំកំណើត ឬ អាយុ របស់សាមីខ្លួន ឪពុក ម្ដាយ និង សាក្សី

- ទីកន្លែងកំណើត (ចំពោះអត្រានុកូលដ្ឋានកំណើត) ទីកន្លែងរៀបអាពាហ៍ពិពាហ៍ (ចំពោះអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍) ទីកន្លែងមរណភាព (ចំពោះអត្រានុកូលដ្ឋានមរណភាព) ។

ទិន្នន័យសំខាន់ ដែលមិនអាចធ្វើការកែតម្រូវ ឬ ផ្លាស់ប្តូរទាំងស្រុងបាន រួមមាន : នាមត្រកូល នាមខ្លួន សញ្ជាតិ ថ្ងៃ ខែ ឆ្នាំកំណើត (ចំពោះអត្រានុកូលដ្ឋានកំណើត) ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍(ចំពោះអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍) និង ថ្ងៃ ខែ ឆ្នាំមរណភាព (ចំពោះអត្រានុកូលដ្ឋានមរណភាព) ។ ការកែតម្រូវអនុញ្ញាតឱ្យធ្វើរៀងផ្ទាត់បានក្នុងករណីមានការខុសឆ្គងខាងអក្ខរាវិរុទ្ធ ឬ ការប្រកបអក្សរប៉ុណ្ណោះ (មានន័យថាសូរសំលេងដូច ឬប្រហាក់ប្រហែលគ្នា ប៉ុន្តែការសរសេរខុសគ្នា) ហើយទោះក្នុងករណីណាក៏ដោយ ការកែតម្រូវនេះ សាមីខ្លួន ឬ អ្នករាយការណ៍ ត្រូវបង្ហាញឯកសារណាមួយ ដែលបញ្ជាក់អំពី នាមត្រកូល នាមខ្លួន សញ្ជាតិ ថ្ងៃ ខែ ឆ្នាំកំណើត ឬ អាពាហ៍ពិពាហ៍ ឬមរណភាព របស់សាមីខ្លួន ឬ របស់អ្នករាយការណ៍ ដូចជា :អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬ សៀវភៅគ្រួសារ ឬ លិខិតឆ្លងដែន ដែលមានសុពលភាព ឬ ឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតចុងក្រោយ សំបុត្រមរណភាពដែលបញ្ជាក់ដោយមន្ទីរពេទ្យ ឬ អាជ្ញាធរមានសមត្ថកិច្ច។

ការផ្លាស់ប្តូរនាមត្រកូល នាមខ្លួន និង សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត អាចធ្វើទៅបានលុះត្រាណា មានសាលក្រមស្ថាពររបស់តុលាការ ឬ មានព្រះរាជក្រឹត្យ ឬ ការសម្រេចណាមួយរបស់រាជរដ្ឋាភិបាល ដោយយោងទៅតាមច្បាប់ ។

ការកែតម្រូវនាមត្រកូល និង នាមខ្លួនអាចធ្វើទៅបាន ប្រសិនបើសាមីខ្លួន ឬ អ្នករាយការណ៍ មានឯកសារដទៃទៀតដូចជា អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ សៀវភៅគ្រួសារ ឬ លិខិតឆ្លងដែន ដែលមានសុពលភាព ឬ ឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតចុងក្រោយ សំបុត្រមរណភាពដែលបញ្ជាក់ដោយមន្ទីរពេទ្យ ឬ អាជ្ញាធរមានសមត្ថកិច្ច ហើយទិន្នន័យនៃឯកសារទាំងនោះ ដូចគ្នាទៅនឹងទិន្នន័យក្នុងបញ្ជីដែលត្រូវកែតម្រូវនោះ ។

ការកែតម្រូវណាមួយដែលទាក់ទងទៅនឹងថ្ងៃ ខែ ឆ្នាំអត្រានុកូលដ្ឋានកំណើត អាពាហ៍ពិពាហ៍ និង មរណភាព នឹងអាចកែតម្រូវបាន លុះត្រាណា មានការសរសេរខុស ដោយការភ័ន្តច្រឡំអចេតនា ហើយសាមីខ្លួន ឬ អ្នករាយការណ៍ ត្រូវតែមានភស្តុតាង នៅក្នុងឯកសារផ្លូវការណាមួយ ដែលបញ្ជាក់អំពី ថ្ងៃ ខែ ឆ្នាំ ឬ អាយុត្រឹមត្រូវរបស់សាមីខ្លួន ដូចបានចែងខាងលើ ។ ដោយឡែក ចំពោះថ្ងៃ ខែ ឆ្នាំកំណើតរបស់ សិស្ស និស្សិត ត្រូវតែបង្ហាញសញ្ញាប័ត្រ ឬ

សៀវភៅសិក្ខាគារិក ជាផ្លូវការ ។ ចំពោះមន្ត្រីរាជការស៊ីវិល នគរបាលជាតិ និង កងយោធពលខេមរភូមិន្ទ ត្រូវមាន ឯកសារបៀវត្ស និង លិខិតបញ្ជាក់ជាផ្លូវការពីអង្គភាព ។

ការកែតម្រូវណាមួយ ដែលមានចេតនា ធ្វើឱ្យប្រាសចាកពី ថ្ងៃ ខែ ឆ្នាំ ឬ អាយុពិតប្រាកដ ត្រូវហាមឃាត់ ជាដាច់ខាត ។

ចំពោះទីកន្លែងកំណើត អាពាហ៍ពិពាហ៍ និង មរណភាព អាចអនុញ្ញាតឱ្យធ្វើការកែតម្រូវបាន ក្នុងករណី មានការខុសឆ្គងផ្នែកអក្ខរាវិរុទ្ធ និង ការប្រកបឈ្មោះភូមិសាស្ត្រ អាស្រ័យដោយមានការភ័ន្តច្រឡំអចេតនា អំពី ឈ្មោះ ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ភូមិ ។

ខ- ទិន្នន័យបន្ទាប់បន្សំ :

ទិន្នន័យបន្ទាប់បន្សំ គឺសំដៅទៅលើការភ័ន្តច្រឡំផ្នែកអក្ខរាវិរុទ្ធ ឬ ការប្រកបឈ្មោះភូមិសាស្ត្រ ឬ ការ ភ្លេចភ្លាំងមិនបានចុះឈ្មោះភូមិសាស្ត្រ ចុះលេខរៀងសៀវភៅ ចុះលេខរៀងបញ្ជី ឬ ចុះលេខរៀងសៀវភៅ ចុះលេខ រៀងបញ្ជីមិនបានត្រឹមត្រូវ ឬ ខ្វះស្នាមមេដៃអ្នករាយការណ៍ សាមីខ្លួន ប្តី ប្រពន្ធ និង សាក្សី ឬ ភ្លេចចុះឈ្មោះ មន្ត្រីអត្រានុកូលដ្ឋាន ឬ ភ្លេចបោះត្រា ...។ល។

ព័ត៌មានបន្ទាប់បន្សំទាំងនេះ មន្ត្រីអត្រានុកូលដ្ឋាន ឬ មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន អាចធ្វើការកែ តម្រូវ និង បំពេញបន្ថែមបាន ដោយមិនចាំបាច់មានការស្នើសុំពីសាមីខ្លួន ឬ អ្នករាយការណ៍ ឬ សាក្សី ឬ ពីតុលាការ ឡើយ ។ ក្នុងការកែតម្រូវ ត្រូវអនុវត្តតាម បទប្បញ្ញត្តិដូចដែលបានចែងក្នុងមាត្រា ១៣ នៃអនុក្រឹត្យស្តីពីអត្រានុ- កូលដ្ឋាន ។ ចំពោះការបំពេញបន្ថែម ត្រូវសរសេរដូសកន្លែងដែលភ្លេចភ្លាំងនោះ ដោយទឹកខ្មៅដូចទឹកខ្មៅដែលបាន ប្រើលើបញ្ជីអត្រានុកូលដ្ឋានទាំងនោះ ។

៥- អំពីរបៀបចាត់ចែងនៃការកែតម្រូវ ឬ បំពេញបន្ថែមនៅក្នុងសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ :

ក- ការកែតម្រូវ ឬ បំពេញបន្ថែមនៅក្នុងសៀវភៅអត្រានុកូលដ្ឋានដែលកំពុងប្រើប្រាស់ :

សៀវភៅអត្រានុកូលដ្ឋានដែលកំពុងប្រើប្រាស់ គឺសំដៅទៅលើសៀវភៅអត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ ដែលកំពុងកត់ត្រាដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ហើយដែលមិនទាន់បានបិទបញ្ជី ។ មានករណីពីរយ៉ាង សម្រាប់កែតម្រូវ ឬ បំពេញបន្ថែម លើបញ្ជីអត្រានុកូលដ្ឋានទាំងនោះ គឺ ÷

ករណីទី១ : ក្រោយពីបានកត់ត្រាចូលក្នុងសៀវភៅភ្លោះ នៃសៀវភៅអត្រានុកូលដ្ឋានរួចហើយ មន្ត្រីអត្រានុ- កូលដ្ឋានត្រូវអាន ឬ ឱ្យសាមីខ្លួន ឬ អាណាព្យាបាល និង សាក្សី ពិនិត្យមើលសៀវភៅភ្លោះទាំងពីរ ។ ប្រសិនបើ ពិនិត្យឃើញថា ត្រឹមត្រូវហើយ ទើបសាមីខ្លួន ឬ អាណាព្យាបាល និង សាក្សី ផ្តិតមេដៃលើបញ្ជីនៃសៀវភៅ អត្រានុកូលដ្ឋានភ្លោះទាំងនោះ ។ បន្ទាប់មកទើបមន្ត្រីអត្រានុកូលដ្ឋាន ចម្លងចូលសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម មួយសន្លឹក ជូនសាមីខ្លួន ឬ អាណាព្យាបាល ទុកជាឯកសារ ។

ក្នុងពេលអាន ឬ ពេលប្រគល់ឱ្យសាមីខ្លួន និង សាក្សីពិនិត្យ ប្រសិនបើមានការខុសឆ្គង ឬ ភ័ន្តច្រឡំ ឬ ខ្វះចន្លោះត្រង់ណា មន្ត្រីអត្រានុកូលដ្ឋានត្រូវកែតម្រូវ ឬ បំពេញបន្ថែមជូន នៅក្នុងបញ្ជីអត្រានុកូលដ្ឋាននោះ នៅចំពោះមុខសាមីខ្លួន ឬ អាណាព្យាបាល និង សាក្សី តាមមាត្រា ១៣ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន ដែលបានកំណត់ថា : " សៀវភៅអត្រានុកូលដ្ឋានទាំងអស់ មិនត្រូវឱ្យមាន កោស ឆូត លុប សរសេរជ្រៀតថែម

